**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្ដាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

**ខុមហ្វ្រែល COMFREL**

**គណៈកម្មាធិការនាយក**
BOARD OF DIRECTORS

លោក **ធន សារាយ**
Mr. THUN SARAY
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

លោក **សុក សំអឿន**
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក CDP

លោក **យឹម ប៉ូ**
Mr. YIM Po អគ្គលេខាធិការ
និង នាយក CCPCR

កញ្ញា **ស៊ុន ចាន់សែន**
Miss. SUN Chansen
ប្រធាន KYA

លោក **មុំ សារិន**
Mr. MOM Sarin
នាយក HRCDO

លោកស្រី **ពឹង យក់ហៀប**
Mr. PEUNG Yok Hiep
នាយិកា LAC

លោកស្រី **ទីវ សារាយេត**
Ms. TIV Sarayet
សហនាយិកា WMC

កញ្ញា **សយ សារា វឌ្ឍនី**
Miss. SAY Sara Vathany
នាយិកា CWCC

លោក **គីម សុវណ្ណ**
Mr. KIM Sovann
នាយក VIGILANCE

លោក **អាង ច័ន្ទឬទ្ធិ**
Mr. ANG Chanrith
នាយក KKKHRO

លោក **យង់ គិមអេង**
Mr. YONG Kim Eng
នាយក PDP-Center

លោក **ភួង សិទ្ធិ**
Mr. PHUONG Sith

លោក **សឺន សែត**
Mr. SEN Set

ស.ប្រ.ក.៣/លេខ ២១/០៩ គ.ប.ស.យ/អ.ក

# សេចក្ដីប្រកាសព័ត៌មាន

## ស្ដីពី

## លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុងខេត្ត ក្រចេះ

*ភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ ៨១នាក់ មកពីស្រុកនានា និងក្រុងក្នុងខេត្តក្រចេះ និងមានសិក្ខាកាមស្ត្រីចូលរួមប្រមាណ៤៣% បានជួបជុំគ្នានៅក្នុងសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តក្រចេះកាលពីថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០០៩ ។

អភិបាលរងខេត្តក្រចេះលោក **ធុន ទ្រី** បានលើកឡើងថា កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលបានកំណត់វិធានការគោលដើម្បីអភិវឌ្ឍន៍កម្ពុជាទាំងផ្នែកសេដ្ឋកិច្ច ស្ថេរភាពនយោបាយ សន្តិសុខ និងធនធានមនុស្ស ហើយសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តក្រចេះនេះ គឺជាការរួមចំណែករបស់សង្គមស៊ីវិលដើម្បីផ្សារភ្ជាប់ពីតម្រូវការរបស់ប្រជាពលរដ្ឋទៅអោយមន្ត្រីជាប់ឆ្នោត ។

អ្នកតំណាងរាស្ត្រ **កាទើ តូយ៉េប** មណ្ឌលក្រចេះមកពីគណបក្សប្រជាជនកម្ពុជា និងសមាជិកក្រុមប្រឹក្សាខេត្តក្រចេះ **ទឹម សុធន់** មកពីគណបក្សសមរង្ស៊ី បានទទួលយកលទ្ធផល និងឯកភាពទាំងស្រុងទៅលើចំនុចទាំង១០ ។

ឯកឧត្តម **កាទើ តូយ៉េប** បានមានប្រសាសន៍ថា " *[ខ្ញុំ] ពាំនាំមតិទាំង ១០ នេះយកទៅថ្នាក់លើជាពិសេសទៅសភាជាតិ* "។

ឯកឧត្តម **ទឹម សុធន់** បានលើកឡើងថា " *ក្នុងនាមខ្ញុំជាសមាជិកក្រុមប្រឹក្សាខេត្តម្នាក់ ខ្ញុំព្យាយាមជួយជំរុញ ជួយដោះស្រាយចំណែកណាដែលតាមលក្ខខណ្ឌរបស់ច្បាប់កំណត់ និងអនុវត្តតាមដែនសមត្ថកិច្ចក្រុមប្រឹក្សា* "។

---

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្ដែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាស់លាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់ ។

ជាលទ្ធផលម្ចាស់ឆ្នោតបានពិភាក្សាកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ ក្នុងខេត្តក្រចេះដូចខាងក្រោមៈ

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំងដប់នៅក្នុងខេត្ត ក្រចេះ** |
|---|
| ១) សុំឱ្យរាជរដ្ឋាភិបាលចេញប័ណ្ណកម្មសិទ្ធិដីធ្លី ជូនដល់ប្រជាពលរដ្ឋឱ្យបានទូទាំងខេត្តក្រចេះ [អោយបាន ១០០%] ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ ២០១៣។ |
| ២) សុំឱ្យរាជរដ្ឋាភិបាលជួយលុបបំបាត់នូវឧបករណ៍នេសាទខុសច្បាប់គ្រប់ប្រភេទ ដូចជា ឆក់ ស្នែមុង លបស្នែ... នៅក្នុងព្រែក បឹង និងទន្លេ ក្នុងខេត្តក្រចេះ ឱ្យបាននៅក្នុង ឆ្នាំ២០១០ នេះតទៅ។ លុបបំបាត់ឱ្យបានការចិញ្ចឹមត្រីឆ្តោរ នៅទូទាំងខេត្តក្រចេះ ចាប់ពីខែ តុលា ឆ្នាំ២០០៩ នេះតទៅ។ |
| ៣) សុំឱ្យតុលាការមានការអនុវត្តច្បាប់ទាំងអស់ ឱ្យមានប្រសិទ្ធិភាព ដោយកុំស៊ីសំណូកតាមគ្រប់រូបភាព និងកុំយកថវិកា [កណ្តាប់ក្តី ] ពីជនរងគ្រោះ [ក្រីក្រ]។ សុំឱ្យអនុវត្ត ចាប់ពីខែតុលា ឆ្នាំ២០០៩ នេះតទៅ។ |
| ៤) ស្នើសុំឱ្យឃើញមានការដកហូត [តំណែង] និងការដាក់ពិន័យយ៉ាងធ្ងន់ស្របតាមច្បាប់ជាមូលដ្ឋាន លើមន្ត្រីដែលបានឃើញថាប្រព្រឹត្តអំពើពុករលួយលើវិស័យព្រៃឈើ ជលផល និងដីធ្លី នៅក្នុងខេត្តក្រចេះ ទាំងមូល ឱ្យបាននៅត្រឹមដើមឆ្នាំ២០១០ នេះតទៅ។ |
| ៥) សុំឱ្យឃើញមានការដាក់ពិន័យរដ្ឋបាល [ អោយស្របតាមការពិន័យដែលមានចែងស្រាប់ ] ដល់បុគ្គលិកពេទ្យដែលមិនមានក្រមសីលធម៌ និងមិនគោរពនូវពេលវេលាធ្វើការនៅគ្រប់មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកទូទាំងខេត្តក្រចេះឱ្យបានយ៉ាងយូរត្រឹមឆ្នាំ២០១០។ |
| ៦) សុំឱ្យរាជរដ្ឋាភិបាលធ្វើការបែងចែកដីសម្បទានសេដ្ឋកិច្ច និងដីព្រៃសហគមន៍ នៅក្នុងភូមិច្រវា ឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ ឱ្យបានដាច់ពីគ្នា យ៉ាងយូនៅក្នុងឆ្នាំ២០០៩។ សុំឱ្យអាជ្ញាធរមានសមត្ថកិច្ចខេត្តក្រចេះ ជួយផ្តល់ដីសម្បទានសង្គមកិច្ចជូនដល់ប្រជាពលរដ្ឋក្រីក្រ និងគ្មានដី (ដីលំនៅដ្ឋាន ដីកសិកម្ម) ស្របតាមអនុក្រឹត្យលេខ១៩ សុំឱ្យបានចាប់ពីខែតុលា ឆ្នាំ២០០៩ នេះតទៅ។ |
| ៧) សុំឱ្យរាជរដ្ឋាភិបាលបង្កើតរោងចក្រស្ករសចំនួន ០១កន្លែង ដែលត្រូវការកំលាំងពលកម្មចំនួន ១៥០-២០០នាក់ នៅក្នុងក្រុងក្រចេះ ខេត្តក្រចេះ ឱ្យបាននៅក្នុង ឆ្នាំ២០១០។ |
| ៨) សុំឱ្យមានការបំបាត់ការរើសអើងចំពោះស្ត្រីអោយបាន១០០% ក្នុងការបញ្ចេញមតិ [អោយមានការបញ្ចេញមតិនៅរាល់កិច្ចប្រជុំ ] ចាប់ពីដើមឆ្នាំ២០១០ នេះតទៅនៅទូទាំងខេត្តក្រចេះ។ |
| ៩) សុំឱ្យរាជរដ្ឋាភិបាល និងសភា ជំរុញអនុម័តច្បាប់ប្រឆាំងអំពើពុករលួយឱ្យបាននៅក្នុងចុងឆ្នាំ២០០៩។ ចាប់ពីឆ្នាំ ២០១០ សុំឱ្យពង្រឹងការផ្តន្ទាទោសដល់ជនប្រព្រឹត្តអំពើពុករលួយឱ្យបានត្រឹមត្រូវតាមនីតិវិធីកំណត់របស់ច្បាប់។ |
| ១០) សុំផ្លូវ ៤ខ្សែៈ ១ខ្សែក្រាលគ្រួសក្រហម ដែលមានប្រវែង ៣គម ទំហំ ៦ម នៅភូមិសោបក្រោម ឃុំសោប ស្រុក ព្រែកប្រសព្វ ខេត្តក្រចេះ ចាប់ផ្តើមដើមឆ្នាំ២០១០ ដល់ចុងឆ្នាំ២០១០។ ១ខ្សែ សុំជួសជុលប្រវែង ៥០០ម ក្រាលគ្រួសក្រហម ដែលមានទំហំ ៦ម នៅក្នុងភូមិច្រវា ឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ ចាប់ពីឆ្នាំ២០១០ ដល់ ឆ្នាំ២០១១។ ១ខ្សែ ក្រាលគ្រួសក្រហម ប្រវែង ៤០គម ទំហំ ៦ម នៅក្នុងភូមិក្បូច ឃុំជីរោទ៍ផុង រហូតដល់ ឃុំកំពង់ជីវ ស្រុកឆ្លូង ខេត្តក្រចេះ ឱ្យបានចាប់ពីឆ្នាំ២០១០ ដល់ ឆ្នាំ២០១១។ ១ខ្សែ ជួសជុលក្រាលគ្រួសក្រហម ប្រវែង ៣គម ទំហំ ៦ម នៅក្នុងភូមិ ព្រែករកា ឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ឱ្យបានចប់ក្នុងដើមឆ្នាំ២០១០ ដល់ចុងឆ្នាំ២០១០។ |

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការខុមហ្វ្រែល សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) អង្គការសហការដើម្បីការអភិវឌ្ឍន៍នៅកម្ពុជា (PADEK) ដែលក្នុងនោះ មានការចូលរួមពីម្ចាស់ឆ្នោត ដែលតំណាងឱ្យសហគមន៍ អង្គការមិនមែន រដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/និស្សិត កសិករ មកពីស្រុកព្រៃកប្រសព្វ ស្រុកចិត្របុរី និងក្រុងក្រចេះ នៅក្នុងខេត្តក្រចេះ។

សិក្ខាសាលាម្ចាស់ឆ្នោតនេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យ ទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*

- លោក **ចំនួ ជារិទ្ធ** អ្នកសម្របសម្រួលផ្នែកព័ត៌មានខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១
- លោក **សុខ ពិនូរៀ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦